# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**⚖**

សាលាដំបូង

ខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៨

ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥។

សាលក្រមលេខ: ០៤ (ឈ)

ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្ត បន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ

នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង៣០ នាទីព្រឹក

ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៨ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ លើជនជាប់ចោទដែលមានឈ្មោះដូច ខាងក្រោម៖

១.ឈ្មោ[redacted]ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិកន្ទូត ឃុំក្ដុល ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានទីលំនៅភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted]ស) ម្ដាយឈ្មោ[redacted])នៅរស់ ទោសពីមុនគ្មាន។

២.ឈ្មោះ **ព្រាំ ប្រយុទ្ធ ហៅឆ្វ** ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខបររត់ម៉ូតូឌុប កើតនៅភូមិគល់គោថ្មី ឃុំសាមគ្គី ស្រុកបាត់ដំបង ខេត្តបន្ទាយមានជ័យ មានទីលំនៅភូមិក្បាលស្ពាន២ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted](រ) ម្ដាយឈ្មោះ[redacted]) ប្រពន្ធឈ្មោះ[redacted]មានកូន០១នាក់ ទោសពីមុនគ្មាន ។

Scanned by CamScanner

ត្រូវជាប់ចោទពីបទ: **ប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន(ច្រើនដង)** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ និងមាត្រា៤៥ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៣១២ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាដំណោះស្រាយលេខ: ២៧៥៧ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៣៥២ ដចត ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ការផ្តល់និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដែលធ្វើឡើងដោយអនុលោមតាមបញ្ញត្តិមាត្រា២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ការប្រព្រឹត្តរបស់ជនត្រូវចោទមានដូចតទៅ:**

កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅចំណុចភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានករណី ប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមួយបានកើតមានឡើង ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted]បានទិញថ្នាំញៀនពីឈ្មោះ[redacted]យកទៅលក់បន្តជាច្រើនលើកច្រើនសារ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ០២ និង៣០នាទី សមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ប៉ោយប៉ែត បានល្បាតនៅក្នុងភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ខេតបន្ទាយមានជ័យ ឃើញជនជាប់ចោទទាំងពីរនាក់ខាងលើកំពុងតែធ្វើសកម្មភាពលក់ដូរថ្នាំញៀន ហើយបានធ្វើចាប់ឃាត់ខ្លួនជនជាប់ចោទទាំងពីរនាក់រួមទាំងវត្ថុតាងមានដូចជាម្សៅក្រាមម៉ាក់ទឹកកកចំនួន០៩កូនថង់តូច, ថង់សម្រាប់វិចខ្ចប់មួយចំនួន, ម៉ូតូមួយគ្រឿងម៉ាកហុងដាសេរីឆ្នាំ២០១៥ ពណ៌ខ្មៅ និងទូរសព្ទដៃ ចំនួន០២គ្រឿងម៉ាកណូគា០១គ្រឿង និងម៉ាកអាយហ្វូន០១គ្រឿង ព្រមទាំងការបូបលុយចំនួន០១ រួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីតែម្តង។

-ក្រោយពីបានស្តាប់ចម្លើយឈ្មោ[redacted]ជាជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយ[redacted]ជាជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិនិត្យនិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

Scanned by CamScanner

## សាលាដំបូងខេត្ត បន្ទាយមានជ័យ

### យល់ឃើញថាៈ

កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅចំណុចភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានករណី ប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតមានឡើង ដែលអំពើនេះបង្ករឡើងដោយជនជាប់ចោទឈ្មោះ [redacted]បានទិញថ្នាំញៀនពីឈ្មោះ [redacted] យកទៅលក់បន្តជាច្រើនលើកច្រើនសារ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង ប្រហែល០២ និង៣០នាទី សមត្ថកិច្ចនគរបាលប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ប៉ោយប៉ែតបាន ល្បាតនៅក្នុងភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ខេតបន្ទាយមានជ័យ ឃើញជនជាប់ចោទទាំងពីរនាក់ ខាងលើកំពុងតែធ្វើសកម្មភាពលក់ដូរថ្នាំញៀន ហើយបានធ្វើចាប់ឃាត់ខ្លួនជនជាប់ចោទទាំងពីរនាក់ រួមទាំងវត្ថុតាងមានដូចជាម្សៅក្រាមម៉ាក់ទឹកកកចំនួន០៩កូនថង់តូច ថង់សម្រាប់វិចខ្ចប់មួយចំនួន ម៉ូតូមួយ គ្រឿងម៉ាកហុងដាសេរីឆ្នាំ២០១៥ ពណ៌ខ្មៅ និងទូរសព្ទដៃចំនួន០២គ្រឿងម៉ាណូគា០១គ្រឿង និងម៉ាក់ អាយហ្វូន០១គ្រឿងៈ ព្រមទាំងការបូបលុយចំនួន០១ រួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្ត បន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីតែម្តង។

-នៅចំពោះមុខតុលាការនាពេលសវនាការឈ្មោ[redacted]ជាជនជាប់ចោទបាន ឆ្លើយបញ្ជាក់ ថាៈ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រភេទខេទឹកកកតាំងពីឆ្នាំ២០១០ រហូតដល់សព្វថ្ងៃ ពេលជក់ដំបូងនោះគឺ មិត្តភ័ក្រ្តទិញយកមកឲ្យជក់ ដោយខ្លួនមិនបាដឹងថាគេទិញពីណាមកទេ។ ចាប់ពីខែកញ្ញា ឆ្នាំ២០១៥ ខ្លួន ចាប់ផ្តើមរកស៊ីលក់ដូរថ្នាំញៀន ដោយថ្នាំញៀននោះខ្លួនបានទិញពីឈ្មោ[redacted]ម្តងចំនួន០២លើក ទៅ០៣ លើក ក្នុងតម្លៃ១២០០បាត (មួយពាន់ពីររយបាតគត់)។ ក្នុង០១លើកយកមករំលែកលក់បន្តក្នុងតម្លៃ ១៤០០បាត (មួយពាន់បួនរយបាតគត់)។ ភាគច្រើនខ្លួនលក់ថ្នាំញៀនឲ្យបុគ្គលិកកាស៊ីណូ ដែលជួលបន្ទប់ ស្នាក់នៅក្នុងក្រុងប៉ោយប៉ែត។ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង០៣ទាបភ្លឺ ខ្លួនបានទៅបន្ទប់ជួះ ជួលរបស់ឈ្មោះ[redacted] ភេទប្រុស ដើម្បីយកថ្នាំញៀនទៅឲ្យវា ពេលទៅដល់ទីនោះស្រាប់តែ មានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ហើយបានដកហូតថ្នាំញៀនចំនួន០៨កូចថង់តូច ទូរសព្ទចំនួន០២គ្រឿង ដែលមានម៉ាកណូគា ពណ៌ខ្មៅ និងម៉ាកអាយហ្វូន ពណ៌ខ្មៅ និងខ្សែក្រវ៉ាត់ចំនួនមួយខ្សែ។ ចំពោះឈ្មោះ [redacted]ធ្លាប់ទិញថ្នាំញៀនពីខ្លួន ហើយបានលក់បន្តទៅឲ្យអ្នកផ្សេងដែរ។ ដោយថ្នាំញៀននេះខ្លួន ទិញតែពីឈ្មោះ[redacted]ទ ក្រៅពីនោះពុំមានទេ។

-ឈ្មោះ [redacted]ជាជនជាប់ចោទបានឆ្លើយបញ្ជាក់ថាៈ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រភេទ ខេទឹកកកតាំងពីឆ្នាំ២០១៣ រហូតមកដល់សព្វថ្ងៃ ហើយនៅពេលដែលជក់ដំបូងនោះគឺមិត្តភក្តិបានទិញ យកមកឲ្យជក់ ប៉ុន្តែមិនដឹងថាពួកវាទិញពីណានោះទេ។ ចាប់ពីខែកញ្ញា ឆ្នាំ២០១៥ ខ្លួនបានចាប់ផ្តើមរកស៊ី លក់ដូរថ្នាំញៀន ដោយខ្លួនបានទិញពីឈ្មោះ [redacted]ម្តងតម្លៃ៨០០បាត (ប្រាំបីរយបាតគត់) ហើយ យកទៅរំលែកសម្រាប់លក់បន្ត ក្នុងមួយកញ្ចប់តូចតម្លៃ៣០០បាតទៅ៥០០បាត។ ភាគច្រើនខ្លួនលក់ថ្នាំ ញៀនទៅឲ្យបុគ្គលិកកាស៊ីណូ ដែលជួលបន្ទប់ស្នាក់នៅក្នុងក្រុងប៉ោយប៉ែត។ នៅថ្ងៃទី០៤ ខែវិច្ឆិកា

Scanned by CamScanner

ឆ្នាំ២០១៥ មានគេទូរសព្ទមកកម្ម៉ង់ទិញថ្នាំញៀនពីខ្លួនចំនួន១៨០០បាត(មួយពាន់ប្រាំបីរយបាតគត់) ខ្លួនបានទូរសព្ទទំនាក់ទំនងទិញថ្នាំញៀនពីឈ្មោះ [redacted] ចំនួន១២០០បាត(មួយពាន់ពីររយបាតគត់)។ ពេលទទួលបានថ្នាំញៀនពីឈ្មោះ [redacted] ហើយខ្លួនមិនទាន់ទាំងបានយកថ្នាំញៀនទៅឲ្យគេផង ស្រាប់តែសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង ហើយបន្តទៅឃាត់ខ្លួនឈ្មោ[redacted] ទៀត ក្រៅពីឈ្មោះ [redacted]នមិនដែលបានទិញថ្នាំញៀនពីអ្នកណាផ្សេងទៀតទេ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ [redacted]មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសបទព្រហ្មទណ្ឌគឺបទ: **ប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង)** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-នៅចំពោះមុខតុលាការនាពេលសវនាការជនជាប់ចោទឈ្មោ[redacted] បានឆ្លើយសារភាពថា: ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ[redacted]ដើម្បីយកទៅលក់បន្តឲ្យទៅឈ្មោះ[redacted]សម្រាប់យកទៅរំលែកលក់បន្តប្រាកដមែន។ ក្រោយមកនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ ពេលខ្លួនយកថ្នាំញៀនទៅប្រគល់ឲ្យឈ្មោះ [redacted]ក្នុងតម្លៃ១២០០បាត(មួយពាន់ពីររយបាតគត់) ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ឃាត់ខ្លួនតែម្តង។

-ចម្លើយរបស់ឈ្មោះ[redacted]ជាជនជាប់ចោទបានឆ្លើយសារភាពថា: នៅខែកញ្ញា ឆ្នាំ២០១៥ ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោ[redacted] យកទៅរំលែកលក់បន្តឲ្យបុគ្គលិកកាស៊ីណូដែលជួលបន្ទប់នៅក្នុងផ្ទះជួលក្រុងប៉ោយប៉ែតប្រាកដមែន។ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ មានគាម្ម៉ង់ទិញថ្នាំញៀនពីខ្លួនចំនួន១៨០០បាត(មួយពាន់ប្រាំបីរយបាតគត់) ខ្លួនក៏បានកម្ម៉ង់ទិញថ្នាំញៀនពីឈ្មោះ [redacted] បន្តចំនួន ១២០០បាត មិនទាន់ទាំងបានយកថ្នាំញៀននោះទៅឲ្យគេផងក៏ត្រូវសមត្ថកិច្ចធ្វើចាប់ឃាត់ខ្លួនតែម្តង។

ដូច្នេះចម្លើយជនជាប់ចោទទាំងពីរនាក់ខាងលើនេះមានភស្តុតាងស៊ីសង្វាក់គ្នា របាយការណ៍បញ្ជូនលេខ: ៣៦១ នប/ក្រប៉ប៉ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់អធិការនគរបាលក្រុងប៉ោយប៉ែតដែរ។

-ការជួញដូរដោយខុសច្បាប់ នូវសារធាតុញៀន របស់ជនជាប់ចោទឈ្មោះ[redacted]និងឈ្មោះ: [redacted]ព្រមទាំងបក្ខពួកយកទៅលក់ ជាអំពើខុសច្បាប់ ដែលមិនអាចអត់អោនឲ្យបានទេព្រោះធ្វើឲ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ និងសន្តិសុខសង្គម បានធ្វើឲ្យជនរងគ្រោះជាប្រជាពលរដ្ឋទទួលរងនូវព្យសនកម្មយ៉ាងធ្ងន់ធ្ងរផ្នែកសម្ភារៈ និងស្មារតីព្រមទាំងធ្វើឲ្យប៉ះពាល់ដល់សុខភាពរហូតដល់បាត់បង់ជីវិតក៏មានដែរ ដូច្នេះជនជាប់ចោទរូបនេះត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់នៅទង្វើប្រព្រឹត្តរបស់ខ្លួន។

-ក្នុងពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានសតិស្មារតីគ្រប់គ្រាន់ ពោលគឺពុំមែនជាជនវិកលចរិត ហើយមានចេតនាប្រព្រឹត្តិយ៉ាងពិតប្រាកដ ទោះបីជាជនជាប់ចោទបានឆ្លើយដោះសារ យ៉ាងណាក៏ដោយ

Scanned by CamScanner

គេចផុតអំពីសំណាញ់នៃច្បាប់បានឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] ទទួលថ្នាំញៀនពីជនជាប់ចោទឈ្មោះ [redacted] យកទៅលក់បន្តឲ្យឈ្មោះ [redacted] អ្នកដទៃទៀតជាច្រើនលើកច្រើនសារ បានន័យថាជននេះជាជនសកម្មក្នុងការប្រព្រឹត្តបទល្មើស ក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន រីឯផលប៉ះពាល់ដល់សង្គមមានកំរិតធ្ងន់ធ្ងរ ដូច្នេះគប្បីតុលាការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទ រូបនេះឲ្យបានសក្តិសមទៅហ្នឹងអំពើប្រព្រឹត្តរបស់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] បានទទួលទិញថ្នាំញៀនពីឈ្មោះ [redacted] ប្រយុទ្ធ យកទៅវែលែកលក់បន្តឲ្យទៅបុគ្គលិកកាស៊ីណូ ដែលជួលបន្ទប់ផ្ទះជួលស្នាក់នៅក្នុងក្រុងប៉ោយប៉ែត ជាច្រើនលើកច្រើនសារ តែរូបភាពនៃ ការជួញដូរ នោះពុំមានលក្ខណៈជាទ្រង់ទ្រាយធំនោះទេ ប៉ុន្តែក្នុងពេលសវនាការជនជាប់ចោទឈ្មោះ [redacted] នេះបានបង្ហការរាំងស្ទះដល់នីតិវិធីសវនាការពុំមានចរិតកែប្រែខ្លួនឲ្យក្លាយជាពលរដ្ឋល្អអាចវិលត្រឡប់ទៅរស់នៅក្នុងសង្គមជាតិវិញបានទេ រីឯជនជាប់ចោទឈ្មោះ [redacted] ក្រោយពេលកើតហេតុបានរត់គេខ្លួនបាត់។ ដូច្នេះគប្បីតុលាការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទរូបនេះឲ្យបានសក្តិសមទៅអំពើប្រព្រឹត្តរបស់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] ក្រោយពេលកើតហេតុបានរត់គេខ្លួនបាត់ គ្មានអត្តសញ្ញាណក្រោយពេលចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឲ្យសមត្ថកិច្ចស្រាវអត្តសញ្ញាណត្រឹមត្រូវតាមច្បាប់រួចហើយតែរកមិនឃើញ ហើយចៅក្រមស៊ើបសួរបានសម្រេចលើកលែងចោទប្រកាន់តាមដីកាដំណោះស្រាយលេខ:២៧៥៧ ចុះថ្ងៃ២៧ ខែមេសា ឆ្នាំ២០១៦ រួចហើយ។

-វត្ថុតាងរួមមាន: ទូរសព្ទម៉ាក់ណូគា (Model.101) ពណ៌ខ្មៅចំនួន០១, ទូរសព្ទដៃម៉ាកណូគាពណ៌ខ្មៅចំនួន០១, ម៉ាកអាយហ្វូន (iphonene) (Model A1387) ចំនួន០១គ្រឿង ដែលជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសគប្បីតុលាការពិចារណាសម្រេចរឹបអូស។

-កាបូបលុយចំនួន០១ មានលុយខ្មែរចំនួន ៦០០០រៀល (ប្រាំមួយពាន់រៀលគត់) និងលុយបាតចំនួន១០០បាត (មួយរយបាតគត់) គប្បីតុលាការពិចារណាសម្រេចរឹបអូស។

-សំណាកថ្នាំញៀនជាម្សៅក្រាមពណ៌សថ្លា មានទម្ងន់សរុប៥,៦ក្រាម (បួនកណ្តក់សញ្ញាប្រាំមួយក្រាមគត់) ដែលនៅសល់ពីការធ្វើកោសលវិច័យ គប្បីតុលាការពិចារណាសម្រេចរឹបអូសនិងបំផ្លាញចោល។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បទ: **ប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន(ច្រើនដង)** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នាពេលសវនាការបានលើកឡើងថា: តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថ្វីត្បិតតែមានការលាក់លៀមខ្លះតែជនជាប់ចោទបានឆ្លើយសារភាពថា

ពិតជាបានទិញថ្នាំញៀនពីឈ្មោះ[redacted]ក្នុងតម្លៃ១២០០០០រៀល(ដប់ពីរម៉ឺនរៀលគត់) យកទៅលក់ឲ្យឈ្មោះ [redacted] ក្នុងតម្លៃ១៨០០០០រៀល(ដប់បួនម៉ឺនរៀលគត់) ពីខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ២០១៥ ប្រាកដមែន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ ដោយឡែកឈ្មោះ [redacted] ក៏ឆ្លើយសារភាពថាពិតជាបានទិញថ្នាំញៀនពីឈ្មោះ [redacted] ក្នុងតម្លៃ១២០០០០រៀល (ដប់ពីរម៉ឺនរៀលគត់) ទៅ១៨០០០០រៀល(ដប់បួនម៉ឺនរៀលគត់) ដើម្បីយកទៅបំបែកលក់ឲ្យបុគ្គលិកកាស៊ីណូប្រាកដមែន ដូច្នេះចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់មានភស្តុតាងស៊ីសង្វាក់គ្នា សុំឲ្យតុលាការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់ នោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] នាពេលសវនាការបានលើកឡើងថា: យោងតាមអង្គហេតុ និងអង្គច្បាប់ និងចម្លើយរបស់កូនក្តីខ្លួនឃើញថា កូនក្តីខ្លួនមិនសក្តិសមនិងត្រូវចោទប្រកាន់ និងឲ្យផ្តន្ទាទោសតាមមាត្រា៥៥ បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឡើយ ដោយពួកគាត់ទាំងពីរនាក់ជាជនរងគ្រោះដោយសារថ្នាំញៀន ដោយសារមិត្តភក្តិលួងលោមបោកប្រាស់ឲ្យប្រើប្រាស់តែប៉ុណ្ណោះ ហើយពួកគាត់ពុំធ្លាប់ទទួលរងនូវវិធានការព្យាបាលដោយបង្ខំម្តងណាឡើយ។ ទន្ទឹមនឹងនេះកូនក្តីរបស់ខ្លួនត្រូវបានតុលាការចោទប្រកាន់មួយករណីទៀតតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ ពីបទៈ **រក្សាទុក ដឹកជញ្ជូនឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**។ កូនក្តីខ្លួនបានទទួលស្គាល់កំហុសរបស់ខ្លួន តាមរយៈចម្លើយសារភាពនិងសហការផ្តល់ព័ត៌មាន តាំងពីជំនាក់កាលឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់បិទការស៊ើបសួរ ដោយមិនបង្កការលំបាកណាមួយដល់ស្ថាប័ណ្ណមានសមត្ថកិច្ចឡើយ។ ដោយយោងតាមភស្តុតាងបញ្ជាក់ឲ្យឃើញថា ការរកស៊ីលក់ដូរគ្រឿងញៀនរបស់កូនក្តីខ្លួនស្ថិតក្នុងបរិមាណតិចតួច គឺគ្រាន់តែបានប្រាក់ចំណេញខ្លះៗសម្រាប់ផ្គត់ផ្គង់ជីវភាព ដែលរកព្រឹកខ្វះល្ងាច នៅក្នុងបន្ទុកមានកូនតូចនិងព្យាបាលម្តាយក្មេកចាស់ជរាកំពុងមានជម្ងឺប្រចាំកាយ។ សេចក្តីសន្និដ្ឋាននេះលក្ខណៈសមហេតុសមផល អាចឲ្យតុលាការលើកយកមកពិចារណាបាន។

នៅក្នុងពេលនេះខ្លួនមានសំណូមពរ សុំឲ្យតុលាការមេត្តាបន្ធូបន្ថយទោសឲ្យកូនក្តីខ្លួនទាំងពីរនាក់ផង។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ សូមឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនផង បញ្ហានេះតុលាការបានពិចារណារួចហើយ។

**ហេតុដូច្នេះសាលាដំបូងខេត្តបន្ទាយមានជ័យ**

**សម្រេចវិនិច្ឆ័យសេចក្តី**

១.ផ្តន្ទាទោសលើជនជាប់ចោទដែលមានឈ្មោះដូចខាងក្រោម៖

ក-ឈ្មោះ[redacted]ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ)។

ខ.ឈ្មោះ[redacted]ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ)។

Scanned by CamScanner

ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំគត់)ក្នុងម្នាក់ៗ គិតពីថ្ងៃឃុំខ្លួនគឺថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០រៀល(ដប់លានរៀលគត់)ក្នុងម្នាក់ៗ ពីបទ:**ប្រើប្រាស់និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន(ច្រើនដង)** ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយ-មានជ័យ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុតាងរួមមាន:

-ទូរសព្ទម៉ាក់ណូគា (Model.101) ពណ៌ខ្មៅចំនួន០១គ្រឿង, ទូរសព្ទដៃម៉ាកណូគាពណ៌ខ្មៅចំនួន០១គ្រឿង,ម៉ាកអាយហ្វូន (iphonene) (Model A1387) ចំនួន០១គ្រឿង ដែលជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសសម្រេចរឹបអូស។

-កាបូបលុយចំនួន០១ មានលុយខ្មែរចំនួន៦០០០រៀល(ប្រាំមួយពាន់រៀលគត់) និងលុយបាតចំនួន១០០បាត(មួយរយបាតគត់)សម្រេចរឹបអូស។

-ម៉ូតូចំនួន០២គ្រឿងគឺ: មួយគ្រឿងម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ គ្មានស្លាកលេខ: មានលេខតួ លេខម៉ាស៊ីន ៩២៨៤៣៩៨ ជារបស់ជនជាប់ចោទឈ្មោះ [redacted] និងមួយគ្រឿងទៀតម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅមានលេខតួ លេខម៉ាស៊ីន៨៧៥៥[redacted] ពាក់ស្លាកលេខតាកែវ ១H.៥២១៣ ជារបស់ជនជាប់ចោទឈ្មោ[redacted]សម្រេចរឹបអូស។

-សំណាកថ្នាំញៀនជាម្សៅក្រាមពណ៌សថ្លាមានទម្ងន់សរុប ៤,៦ក្រាម (បួនក្បៀសប្រាំមួយក្រាមគត់) ដែលនៅសល់ពីការធ្វើកោសលវិច័យ គប្បីតុលាការពិចារណាសម្រេចរឹបអូសនិងបំផ្លាញចោល។

៣.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទ។

បើកផ្លូវប្តឹង ឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| **ហត្ថលេខានិងត្រ**[redacted] | [redacted] [redacted] | **ហត្ថលេខានិងត្រា**[redacted] |

**បានឃើញ**

បន្ទាយមានជ័យ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧

**ចៅក្រម**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

បន្ទាយមានជ័យ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

[redacted]

Scanned by CamScanner